ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៩៧ ព.ណ.ជអ.ប្រក

# ប្រកាស
# ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១** :

នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម មានមុខងារ និងភារកិច្ចដូចតទៅៈ

- ជួយរកទីផ្សារជូនកសិករ និងពាណិជ្ជករ
- ស្រាវជ្រាវ និងអភិវឌ្ឍន៍ទីផ្សារ
- រៀបចំយុទ្ធសាស្ត្រស្វែងរកទីផ្សារ ស្រាវជ្រាវវិភាគ និងកសាងគោលនយោបាយទីផ្សារ និងជំរុញការនាំចេញ
- រៀបចំ និងទទួលបេសកកម្មពាណិជ្ជកម្មក្នុង និងក្រៅប្រទេស ក្នុងបំណងបង្កើតនូវវេទិកាដៃគូពាណិជ្ជកម្ម ឬជំនួបពាណិជ្ជកម្ម សម្រាប់ពាណិជ្ជកម្មក្នុង និងក្រៅប្រទេស ដោយសហការជាមួយអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស



ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA
ទូរស័ព្ទ / ទូរសារៈ(៨៥៥)-២៣ ៨៦៦ ៤៦៩
Phone/Facsimile: (855)-23 866 469

- សហប្រតិបត្តិការជាមួយដៃគូជំរុញពាណិជ្ជកម្ម និងមជ្ឈមណ្ឌលជំរុញពាណិជ្ជកម្ម ក្នុងតំបន់ និងពិភពលោក រួមមានមជ្ឈមណ្ឌលជំរុញពាណិជ្ជកម្មអាស៊ាន-ជប៉ុន មជ្ឈមណ្ឌលជំរុញពាណិជ្ជកម្មអាស៊ាន-ចិន មជ្ឈមណ្ឌលជំរុញពាណិជ្ជកម្មអាស៊ាន-កូរ៉េ វេទិកាជំរុញពាណិជ្ជកម្មអាស៊ី
- រៀបចំ និងចាត់ចែងសិក្ខាសាលា សន្និសីទ វេទិកាពាណិជ្ជកម្ម និងកិច្ចការប្រជុំស្តីពីកិច្ចការជំរុញពាណិជ្ជកម្ម សម្រាប់បង្កើតឲ្យមានដៃគូពាណិជ្ជកម្ម
- សិក្សាស្រាវជ្រាវលើផលិតផលថ្មីៗ និងការអភិវឌ្ឍន៍ផលិតផល ដែលជាសក្តានុពលសម្រាប់បម្រើទីផ្សារក្នុងស្រុក និងទីផ្សារនាំចេញ ដោយសហការជាមួយអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស
- ចូលរួមអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ជាមួយស្ថាប័នពាក់ព័ន្ធ
- ផ្តល់សេវាពិគ្រោះយោបល់ និងប្រឹក្សាលើកិច្ចការទីផ្សារ និងពាណិជ្ជកម្ម
- ផ្សព្វផ្សាយព័ត៌មាន ដែលទាក់ទងជាមួយការងារជំរុញពាណិជ្ជកម្ម និងទីផ្សារក្រៅប្រទេស
- ផ្សព្វផ្សាយ និងទំនាក់ទំនងជាមួយទីផ្សារអន្តរជាតិ
- គ្រប់គ្រងមជ្ឈមណ្ឌលជំរុញពាណិជ្ជកម្មក្នុង និងក្រៅប្រទេស
- ចងក្រង និងផ្សព្វផ្សាយសៀវភៅនីតិវិធីនាំចេញ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ២** :

នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ។

**ប្រការ ៣** :

នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ មានការិយាល័យចំណុះចំនួន ០៤ គឺ៖

១- ការិយាល័យសហប្រតិបត្តិការដៃគូពាណិជ្ជកម្ម

២- ការិយាល័យយុទ្ធសាស្ត្រជំរុញទីផ្សារ

៣- ការិយាល័យទំនាក់ទំនងតំណាងពាណិជ្ជកម្មក្រៅប្រទេស

៤- ការិយាល័យផ្តល់សេវាព័ត៌មានទីផ្សារ និងផ្សព្វផ្សាយ

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ ៤** :

ការិយាល័យសហប្រតិបត្តិការដៃគូពាណិជ្ជកម្ម មានភារកិច្ច៖

- រៀបចំ និងទទួលបេសកម្មពាណិជ្ជកម្មក្នុង និងក្រៅប្រទេស ក្នុងបំណងបង្កើតនូវវេទិកាដៃគូពាណិជ្ជកម្ម ឬជំនួបពាណិជ្ជកម្ម សម្រាប់ពាណិជ្ជកម្មក្នុង និងក្រៅប្រទេស ដោយសហការជាមួយអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស

- សម្របសម្រួល និងរៀបចំបេសកកម្មពាណិជ្ជកម្មរកទីផ្សារក្រៅប្រទេស
- រៀបចំទទួល និងសម្របសម្រួលប្រតិភូពាណិជ្ជកម្មលើកិច្ចជំនួបពាណិជ្ជកម្ម និងការងារពាក់ព័ន្ធនឹងកិច្ចការជំរុញពាណិជ្ជកម្ម
- សហប្រតិបត្តិការជាមួយដៃគូជំរុញពាណិជ្ជកម្ម និងមជ្ឈមណ្ឌលជំរុញពាណិជ្ជកម្មក្នុងតំបន់ និងពិភពលោក រួមមានមជ្ឈមណ្ឌលជំរុញពាណិជ្ជកម្មអាស៊ាន-ជប៉ុន មជ្ឈមណ្ឌលជំរុញពាណិជ្ជកម្មអាស៊ាន-ចិន មជ្ឈមណ្ឌលជំរុញពាណិជ្ជកម្មអាស៊ាន-កូរ៉េ វេទិកាជំរុញពាណិជ្ជកម្មអាស៊ី
- រៀបចំ និងចាត់ចែងសិក្ខាសាលា សន្និសីទ វេទិកាពាណិជ្ជកម្ម និងកិច្ចប្រជុំស្តីពីកិច្ចការជំរុញពាណិជ្ជកម្ម សម្រាប់បង្កើតឲ្យមានដៃគូពាណិជ្ជកម្ម និងជំនួបពាណិជ្ជកម្ម
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៥** :

ការិយាល័យយុទ្ធសាស្ត្រជំរុញទីផ្សារ មានភារកិច្ចៈ

- ជួយរកទីផ្សារជូនកសិករ និងពាណិជ្ជករ
- រៀបចំយុទ្ធសាស្ត្រស្វែងរកទីផ្សារ ស្រាវជ្រាវវិភាគ និងចូលរួមកសាងគោលនយោបាយទីផ្សារ និងជំរុញការនាំចេញ
- ធ្វើចារកិច្ចទីផ្សារក្នុង និងក្រៅប្រទេស
- ពង្រីកទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ដើម្បីផ្សារភ្ជាប់ទីផ្សារក្នុងប្រទេស ជាមួយនឹងទីផ្សារក្រៅប្រទេស និងលើកកម្ពស់ការផលិត ផ្គត់ផ្គង់ ជំរុញវិនិយោគ និងនាំចេញ
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីទីផ្សារ
- ចូលរួមអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីអភិវឌ្ឍន៍ការនាំចេញ
- សិក្សាស្រាវជ្រាវលើផលិតផលថ្មីៗ និងការអភិវឌ្ឍន៍ផលិតផលដែលជាសក្តានុពលសម្រាប់បម្រើទីផ្សារក្នុងស្រុក និងទីផ្សារនាំចេញ
- រៀបចំ និងចាត់ចែងទិវាផលិតផលដែលមានសក្តានុពល ដូចជាទិវាអង្ករ ទិវាបន្លែ និងផ្លែឈើ
- ទំនាក់ទំនងការងារជំរុញពាណិជ្ជកម្ម ជាមួយការិយាល័យជំរុញពាណិជ្ជកម្មរាជធានី ខេត្ត
- រៀបចំសកម្មភាពលើកកម្ពស់ និងអភិវឌ្ឍន៍ទីផ្សារ ចំពោះផលិតផលដែលទើបរកឃើញថ្មីៗ និងផលិតផលដែលមានស្រាប់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៦** :

ការិយាល័យទំនាក់ទំនងតំណាងពាណិជ្ជកម្មក្រៅប្រទេស មានភារកិច្ចៈ

- ទទួលបន្ទុកជាលេខាធិការដ្ឋានទំនាក់ទំនងជាមួយស្ថានតំណាងពាណិជ្ជកម្មក្រៅប្រទេស

- គ្រប់គ្រងមជ្ឈមណ្ឌលជំរុញពាណិជ្ជកម្មក្នុង និងក្រៅប្រទេស
- រៀបចំសម្របសម្រួល ផ្តល់ឯកសារ ព័ត៌មានពាណិជ្ជកម្ម គោលនយោបាយពាណិជ្ជកម្ម និងដល់ស្ថានតំណាងពាណិជ្ជកម្មក្រៅប្រទេស
- សហការជាមួយតំណាងពាណិជ្ជកម្មនៅក្រៅប្រទេស ក្នុងការរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំ ដើម្បីធានាការអនុវត្តន៍ការងារឲ្យមានប្រសិទ្ធភាព
- សរុប និងវិភាគរបាយការណ៍ពាណិជ្ជកម្ម ដែលទទួលបានពីតំណាងពាណិជ្ជកម្មក្រៅប្រទេស ដាក់ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៧** :

ការិយាល័យផ្តល់សេវាព័ត៌មានទីផ្សារ និងផ្សព្វផ្សាយ មានភារកិច្ចៈ

- ផ្សព្វផ្សាយព័ត៌មានដែលទាក់ទងជាមួយការងារជំរុញពាណិជ្ជកម្ម និងទីផ្សារក្រៅប្រទេស
- សិក្សាស្រាវជ្រាវ រៀបចំ និងចងក្រងផែនទីទីផ្សារ
- បន្តធ្វើបច្ចុប្បន្នភាពសៀវភៅនីតិវិធីនាំចេញ
- រៀបចំ ចងក្រង និងបោះពុម្ពសៀវភៅ ឯកសារ ខិតប័ណ្ណផ្សព្វផ្សាយ ទស្សនាវដ្តី ទីផ្សារ
- ផ្តល់សេវាពិគ្រោះយោបល់ និងប្រឹក្សាលើកិច្ចការទីផ្សារ និងពាណិជ្ជកម្ម
- រៀបចំកិច្ចការរដ្ឋបាលរបស់នាយកដ្ឋាន ដូចជាការងាររៀបចំរបាយការណ៍បូកសរុបប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំរបស់នាយកដ្ឋាន និងកិច្ចការមន្ត្រី
- បង្ហាញ និងណែនាំដល់ផលិតករ កសិករ អំពីតម្រូវការផលិតផលលើទីផ្សារគោលដៅ
- សិក្សាស្រាវជ្រាវទិន្នន័យទីផ្សារ និងចងក្រងអំពីការផ្គត់ផ្គង់ និងតម្រូវការទីផ្សារ
- រៀបចំ និងគ្រប់គ្រងគេហទំព័ររបស់អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៨** :

ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៩** :

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានអង្គភាពចំណុះក្រសួង ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ស៊ុន ចាន់ថុល**

<u>កន្លែងទទួលៈ</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងមុខងារសាធារណៈ
-ដូចប្រការ៩
-ឯកសារ-កាលប្បវត្តិ

# រចនាសម្ព័ន្ធរបស់នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ

